# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

### ខែមេសា ឆ្នាំ២០២០ /April 2020

**មាតិកា**


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប/Executive summary** | **១** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends** | **៣** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់/Consumer price index | ៣ |
| ១.២. វិស័យពាណិជ្ជកម្ម/Trade | ៤ |
| ១.៣. ការអនុវត្តថវិកា/Budget execution | ៧ |
| ១.៤. វិស័យវិនិយោគឯកជន/Private investment | ៩ |
| ១.៥. វិស័យទេសចរណ៍/Tourism | ១១ |
| ១.៦. វិស័យសំណង់/Construction | ១២ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗ /Commodity prices** | **១៣** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ១៣ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១៤ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១៥ |
| **៣. ឧបសម្ព័ន្ធ** | **១៧** |

## ខ្លឹមសារសង្ខេប / Executive summary

**១.** ក្នុងរយៈពេល៤ខែ ឆ្នាំ២០២០នេះ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិសរុប ១,២ លាននាក់ បានធ្លាក់ចុះ -៥២% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ដែលមួយផ្នែកធំបណ្តាលមកពីការធ្លាក់ចុះនៃភ្ញៀវទេសចរចិន។ ជាក់ស្តែងភ្ញៀវទេសចរចិនមានចំនួន ២៦៣ ពាន់នាក់ (២២,៧% នៃភ្ញៀវទេសចរអន្តរជាតិសរុប) បានធ្លាក់ចុះ -៧០,៤% និងរួមចំណែកដល់ការធ្លាក់ចុះ (contribution to decline) -២៥,៩%។ ទន្ទឹមនេះ, ភ្ញៀវទេសចរអន្តរជាតិ ដែលមកទស្សនាប្រទេសកម្ពុជាខ្ពស់បំផុតទាំង១០ លើកលែងប្រទេសថៃ (កើនឡើង ២១%[1]) សុទ្ធតែមានកំណើនអវិជ្ជមាន។ គួរបញ្ជាក់ផងដែរថា ភ្ញៀវទេសចរអន្តរជាតិ ដែលចូលតាមផ្លូវអាកាស បានធ្លាក់ចុះ -៦០% ក្នុងនោះ ចំនួនភ្ញៀវទេសចរអន្តរជាតិចូលតាមច្រកអាកាសយានដ្ឋានភ្នំពេញ, សៀមរាប និងកងកេង បានធ្លាក់ចុះ -៥១,៤%, -៦៧,០% និង -៦៨,៩% រៀងគ្នា។ ជាក់ស្តែង ចំនួនភ្ញៀវទេសចរអន្តរជាតិទិញសំបុត្រចូលទស្សនារមណីយដ្ឋានអង្គរបានធ្លាក់ចុះ -៦០,៥% និងចំណូលពីការលក់សំបុត្រចូលទស្សនាក៏បានធ្លាក់ចុះ -៥៩,៣%[2]។

**២.** ក្នុងរយៈពេល៤ខែ ឆ្នាំ២០២០[3]នេះ ការនាំចេញទំនិញរបស់កម្ពុជា សម្រេចបានក្នុងទំហំទឹកប្រាក់សរុប ៤ ៤៣០ លានដុល្លារ បានកើនឡើង ៧,៧% (ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន) ទាបជាងកំណើនក្នុងពេលដូចគ្នាឆ្នាំមុន ដែលមានអត្រា ១៤,៣%។ ជារួម ទឹកប្រាក់នាំចេញនៅរក្សាបានកំណើនល្អ ទោះបីជា បណ្តាប្រទេសដៃគូពាណិជ្ជកម្ម និងសកល កំពុងជួបបញ្ហាប្រឈមនៃការរីករាលដាលនៃវីរុសកូវីដ-១៩ ក៏ដោយ។ ការរក្សាបានកំណើននេះ មួយផ្នែកបណ្តាលមកពីការសម្រេចបានកំណើនខ្ពស់នៃទឹកប្រាក់នាំចេញក្នុងខែមករា និងកុម្ភៈ ដើមឆ្នាំនេះ ពោលគឺបានកើនឡើង ២៥,៤% និង ២២,៨% រៀងគ្នា (ធៀបខែដូចគ្នាឆ្នាំមុន)។ ប៉ុន្តែ បើពិនិត្យលើស្ថានភាពទឹកប្រាក់នាំចេញក្នុងខែមីនា និងមេសា ឆ្នាំ២០២០នេះវិញ កំណើននាំចេញមានការធ្លាក់ចុះក្នុងអត្រាអវិជ្ជមាន -១៥,៣% និង -០,៥% រៀងគ្នា។ ទន្ទឹមនេះ ការនាំចូលមានទំហំទឹកប្រាក់សរុប ៦ ៧៣៦ លានដុល្លារ បានកើនឡើងត្រឹមតែ ៦,៧% (ធៀបរយៈពេលដូចគ្នាឆ្នាំមុន) ទាបជាងកំណើនក្នុងរយៈពេលដូចគ្នាឆ្នាំមុន ដែលមានអត្រា ២៥,១%។ ការថមថយកំណើនទឹកប្រាក់នាំចូលទំនិញនេះ បណ្តាលមកពីការថមថយកំណើនទឹកប្រាក់នាំចូល ក្នុងអំឡុងខែមីនា មកត្រឹមអត្រា ០,៤% (ធៀបនឹងខែដូចគ្នាឆ្នាំមុន) និងការធ្លាក់ចុះកំណើនក្នុងអត្រាអវិជ្ជមាន -១៣,៩% ក្នុងខែមេសា។ មួយវិញទៀត ការនាំចូលទំនិញចម្បងៗមានការធ្លាក់ចុះ ជាពិសេស គ្រឿងសំណង់, ផលិតផលវាយនភណ្ឌ (ពិសេសក្រណាត់) និងគ្រឿងយន្ត។

**៣.** ក្នុងរយៈពេល៤ខែ ឆ្នាំ២០២០នេះ សំណើសុំសាងសង់សរុបមានចំនួន ១ ៦៤៧ គម្រោង បានកើនឡើង ៣២២ គម្រោង ដែលមានផ្ទៃក្រឡា ៦,៨ លានម៉ែត្រការ៉េ និងមានតម្លៃ ៣ ០៤៩ លានដុល្លារ បានកើនឡើង ២០,៥% និង ១២,១% រៀងគ្នា ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ រីឯសំណង់ប្រភេទលំនៅដ្ឋានមាន ១ ៣៤៥ គម្រោង (កើន ២២៣ គម្រោង), សំណង់ប្រភេទឧស្សាហកម្មមាន ៦៣ គម្រោង (កើន ៩ គម្រោង), សំណង់ប្រភេទសាធារណៈមាន ៤៤ គម្រោង (កើន ១៨ គម្រោង), សំណង់ប្រភេទទេសចរណ៍មាន ៣៨ គម្រោង (កើន ៨ គម្រោង), សំណង់ប្រភេទពាណិជ្ជកម្មមាន ១៥៥ គម្រោង (កើន ៧៦ គម្រោង) ប៉ុន្តែសំណង់ប្រភេទវិនិយោគមាន ២ គម្រោង (ធ្លាក់ចុះ ១២ គម្រោង)។ ជាការកត់សម្គាល់ ការស្នើសុំគម្រោងលំនៅដ្ឋានចាប់ផ្តើមងើបឡើងបណ្តើរៗ ប៉ុន្តែការអនុវត្តគម្រោងសាងសង់អាចចាប់ផ្តើមពេលការរីករាលដាលនៃវីរុសកូវីដ-១៩ ត្រូវបានបញ្ចប់។ ជាក់ស្តែងការនាំចូលគ្រឿងសំណង់ដែល

---

[1] កំណើននេះដោយសារការកើនឡើងខ្លាំងនៃភ្ញៀវទេសចរថៃនៅត្រីមាសទី១។ ចំនួនភ្ញៀវទេសចរថៃក្នុងខែមេសា មានត្រឹមតែ ១ ១៥៧ នាក់ ថយចុះ -៩៦% ធៀបនឹងខែមេសាឆ្នាំមុន។

[2] ទិន្នន័យរបស់គ្រឹះស្ថានអង្គរ ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០។

[3] ទិន្នន័យរដ្ឋបាល (admin data) ដែលទទួលបានពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករ នៅថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០២០។

មានទឹកប្រាក់សរុប ៣៧២ លានដុល្លារ បានធ្លាក់ចុះកំណើនក្នុងអត្រាអវិជ្ជមាន -១១,៧% មួយផ្នែកដោយសារការបន្តធ្លាក់ចុះខ្លាំងនៃទឹកប្រាក់នាំចូលដែក[4]។ ចំណែកឯ ការនាំចូលសម្ភារសំណង់ផ្សេងៗនៅតែបន្តថមថយកំណើន ពោលគឺ មានទឹកប្រាក់នាំចូលសរុប ២៤៧ លានដុល្លារ បានកើនឡើង ២,១% ទាបជាងកំណើនក្នុងឆ្នាំមុន ដែលមានអត្រារហូតដល់ ៧៨,៩%។

**៤.** ក្នុងរយៈពេល៤ខែ ឆ្នាំ២០២០នេះ គម្រោងវិនិយោគឯកជនសរុប[5] មានចំនួន ៧៧ គម្រោង បានកើនឡើង ១ គម្រោង និងមានទុនវិនិយោគ ប្រមាណ ១ ៥២៧ លានដុល្លារ ថយចុះ -៥៧,៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ក្នុងចំណោមគម្រោងទាំង ៧៧ នេះ, ៦៨ គម្រោង ជាវិនិយោគក្នុងវិស័យឧស្សាហកម្ម (៩ លើរោងចក្រកាបូប, ២៣ លើរោងចក្រកាត់ដេរសម្លៀកបំពាក់), ៣ គម្រោងក្នុងវិស័យទេសចរណ៍, និង ៤ គម្រោងក្នុងវិស័យសេវាកម្ម។ បើធៀបនឹងរយៈពេល៤ខែ ឆ្នាំ២០១៩, គម្រោងវិនិយោគក្នុងវិស័យឧស្សាហកម្ម បានកើនឡើងត្រឹមតែ ១ គម្រោង ក្នុងនោះ គម្រោងវិនិយោគលើរោងចក្រគ្រឿងបន្សំសម្លៀកបំពាក់ (garment accessories) បានកើនឡើង ៦ គម្រោង។ ទន្ទឹមនឹងនេះ ស្ថានភាពវិនិយោគអាចប្រឈមនឹងភាពទ្រុឌទ្រោម ដោយសារការអូសបន្លាយនៃការរីករាលដាល នៃវីរុសកូវីដ-១៩ ព្រោះ តម្រូវការ (demand side) នឹងធ្លាក់ចុះខ្លាំង ដោយសារ ជាទូទៅក្នុងស្ថានភាពបែបនេះ អ្នកប្រើប្រាស់តែងតែត្បិតត្បៀតខ្លាំងក្នុងការចំណាយ ពិសេសអ្នកប្រើប្រាស់ក្នុងទីផ្សារនាំចេញធំរបស់កម្ពុជា រួមមានអាមេរិក និងសហគមន៍អឺរ៉ុប ដែលសុទ្ធសឹងជាប្រទេសកំពុងប្រឈមការឆ្លងវីរុសកូវីដ-១៩។

**៥.** នៅខែមេសា ឆ្នាំ២០២០នេះ, អត្រាកំណើនសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្ម មានការថមថយធៀបនឹងខែដូចគ្នាឆ្នាំមុន ពោលគឺបានកើនឡើង ១,៩% ទាបជាងឆ្នាំមុនដែលមានអត្រា២,១%។ ការថមថយនេះបណ្តាលមកពីការថមថយសន្ទស្សន៍ថ្លៃក្រុមទំនិញនិងសេវាកម្មភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់, សម្លៀកបំពាក់និងស្បែកជើង, ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត, គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ, សុខាភិបាល, និងភោជនីយដ្ឋាន។ ដោយឡែក សន្ទស្សន៍ថ្លៃដឹកជញ្ជូន ដែលមានការធ្លាក់ចុះយ៉ាងគំហុក បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

**៦.** ក្នុងរយៈពេល៤ខែ ឆ្នាំ២០២០នេះ រដ្ឋបាលថ្នាក់ជាតិប្រមូលចំណូលក្នុងស្រុកសរុបបានចំនួន ៨ ២០០,១៥ ប៊ីលានរៀល ឬស្មើនឹង ៣៤,០៤% នៃច្បាប់ឆ្នាំ២០២០ បានកើនឡើង ១១,១៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណាយសរុបបានចំនួន ៧ ៣៣៦,៤២ ប៊ីលានរៀល ឬស្មើនឹង ២៤,៤៦% នៃច្បាប់២០២០ បានកើនឡើង ៣១,០៤%។ ជាលទ្ធផល គិតត្រឹមខែមេសា ឆ្នាំ២០២០ តុល្យភាពថវិកាចរន្តនៅតែអាចសម្រេចបានអតិរេកសាច់ប្រាក់ចំនួន ២ ៥៩៧,៣២ ប៊ីលានរៀល។

**៧.** នៅខែមេសា ឆ្នាំ២០២០ ថ្លៃប្រេងសាំងធម្មតា និងប្រេងម៉ាស៊ូតលើទីផ្សារកម្ពុជា ព្រមទាំងថ្លៃប្រេងឆៅលើទីផ្សារអន្តរជាតិ បានថយចុះខ្លាំងធៀបនឹងខែមុន។ ចំណែកឯ ថ្លៃអង្ករផ្កាម្លិះ និងអង្ករនាងមិញលើទីផ្សារកម្ពុជា បានកើនឡើងបន្តិច ស្របពេលដែល ថ្លៃអង្ករ លើទីផ្សារអន្តរជាតិ បន្តកើនឡើងខ្លាំង។ ដោយឡែក ថ្លៃកៅស៊ូគ្រួសារជ័រកៅស៊ូស្ងួត បានថយចុះបន្តិច ខណៈពេលដែល ថ្លៃកៅស៊ូថៃ TSR20 និងថ្លៃកៅស៊ូថៃ RSS3 នៅតែបន្តថយចុះ។

---

[4] ក្នុងរយៈពេល ៤ខែ ឆ្នាំ២០២០ ការនាំចូលដែកមានទឹកប្រាក់សរុបមានចំនួន ៩៤ លានដុល្លារ បានធ្លាក់ចុះក្នុងអត្រាអវិជ្ជមាន -៣៧,៦% (ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន) ខណៈដែលរយៈពេលដូចគ្នាឆ្នាំមុន មានកំណើនរហូតដល់ ៥៧,៦%។

[5] គម្រោងវិនិយោគឯកជនក្រៅតំបន់សេដ្ឋកិច្ចពិសេស ដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

# ៣. ឧបសម្ព័ន្ធ

## ១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends

### ១.១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index







ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ

**ក្រាហ្វិកបម្រែបម្រួលអត្រាអតិផរណាប្រទេសកម្ពុជាឆ្នាំ ២០១៨-២០២០**




*ប្រភពទិន្នន័យ÷ វិទ្យាស្ថានជាតិស្ថិតិកម្ពុជា(NIS)

## ១.២. វិស័យពាណិជ្ជកម្ម / Trade













ប្រភព÷ GDCE, MEF

**ការនាំចេញផលិតផលវាយនភណ្ឌទៅកាន់ទីផ្សារសំខាន់ៗមាន**
**ការធ្លាក់ចុះ និងថមថយកំណើនគួរឱ្យកត់សម្គាល់**




**ស្ថានភាពនាំចេញអង្ករកម្ពុជាមានកំណើនឡើងវិញបន្តិច**
**ជាពិសេសការនាំចេញទៅកាន់សហភាពអឺរ៉ុប និងអង់គ្លេស**




**ការនាំចេញកង់ទៅសហភាពអឺរ៉ុបដែលជាទីផ្សារធំរបស់កម្ពុជាបានធ្លាក់ចុះបន្តិច**
**ខណៈពេលទីផ្សារអង់គ្លេស និងអាមេរិកមានកំណើន**




**ការនាំចូលទំនិញសំខាន់ៗមានការធ្លាក់ចុះកំណើនគួរឱ្យកត់សម្គាល់នាដើមឆ្នាំនេះ**
**ខណៈពេលដែលការនាំចូលប្រេងឥន្ធនៈមានកំណើនទាប**




ប្រភព÷ GDCE, MEF

### ទឹកប្រាក់នាំចូលក្រណាត់នៅតែបន្តធ្លាក់ចុះគួរឱ្យកត់សម្គាល់ ក្នុងរយៈពេល ៤ខែ ឆ្នាំ២០២០នេះ




### ការនាំចូលដែកបានធ្លាក់ចុះកំណើនក្នុងអគ្រាអវិជ្ជមាន ខណៈ ដែលស៊ីម៉ងត៍ និងសម្ភារៈសំណង់ផ្សេងៗអាចរក្សាបានកំណើន




### បរិមាណការនាំចូលរថយន្តបានធ្លាក់ចុះកំណើនក្នុងអត្រាអវិជ្ជមាន ជាពិសេសរថយន្តទេសចរណ៍




### បរិមាណនាំចូលប្រេងសាំង និងប្រេងម៉ាស៊ូត មានការថមថយកំណើន ស្របពេលប្រេងឥន្ធនៈផ្សេងៗកំពុងធ្លាក់ចុះកំណើនអវិជ្ជមាន




ប្រភព៖ GDCE, MEF

## ១.៣. ការអនុវត្តថវិការដ្ឋ / Budget execution







ប្រភព ÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ១.៥. ស្ថានភាពវិនិយោគ / Investment







ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ១.៦. ស្ថានភាពទេសចរណ៍ / Tourism




ប្រភព÷ ក្រសួងទេសចរណ៍

## ១.៧. ស្ថានភាពសំណង់ / Construction




ប្រភព÷ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity prices




ប្រភព÷ ក្រសួងពាណិជ្ជកម្ម




ប្រភព÷ ធនាគារពិភពលោក (Pink Sheet)




ប្រភព÷ ក្រសួងពាណិជ្ជកម្ម




ប្រភព÷ ធនាគារពិភពលោក (Pink Sheet)




ប្រភព÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




ប្រភព÷ Association of Natural Rubber Producing Countries (ANRPC)

**************

**<u>កំណត់សម្គាល់</u>**

កៅស៊ូ÷

- កៅស៊ូ TSR20: ឬហៅថាកៅស៊ូស្តង់ដារលេខ២០ រួមមានកៅស៊ូ SIR20, SMR20 និង STR20 គឺសំដៅលើកៅស៊ូធម្មជាតិដែលមានសារធាតុផ្សេងៗទៀត២០%។ កៅស៊ូធម្មជាតិមានច្រើនប្រភេទ ក្នុងនោះកៅស៊ូដែលមានតម្រូវការប្រើប្រាស់ច្រើនជាងគេគឺកៅស៊ូស្តង់ដារ (កៅស៊ូដុំ) និងកៅស៊ូបន្ទះ។ កៅស៊ូ TSR20 ជាប្រភេទកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ ផលិតកម្មកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើងនិងអាវភ្លៀងជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយលាយបញ្ចូល ជាមួយសារធាតុដទៃ ដែលធ្វើឱ្យផលិតផលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំ ធន់និងមិនងាយសឹករិចរិល។ ប្រទេសសំខាន់ៗដែលផលិតកៅស៊ូប្រភេទនេះគឺម៉ាឡេស៊ី ថៃ ឥណ្ឌូណេស៊ី វៀតណាម និងចិន។
- កៅស៊ូ RSS (Ribbed Smoked Sheets) បែងចែកជា៦ប្រភេទគឺ ប្រភេទលេខ 1, 2, 3, 4, 5 និងប្រភេទពិសេស មានពណ៌លឿងនិងវេចខ្ចប់ជាបន្ទះ។ កៅស៊ូប្រភេទ RSS3 ច្រើនផលិតនៅប្រទេសថៃ ឥណ្ឌា និងឥណ្ឌូណេស៊ី ប្រើប្រាស់ជាវត្ថុធាតុ សម្រាប់ផលិតសំបកកង់រថយន្ត បំពង់ទីបជ័រ និងស្បែកជើង។ កៅស៊ូប្រភេទនេះប្រើប្រាស់ក្នុងឧស្សាហកម្មផលិតសំបកកង់ រថយន្ត និងដែលជាធាតុផ្សំលើស 50% នៃផលិតផល។

ប្រេងឆៅ÷

ប្រេងឆៅ Brent, WTI និង Dubai ជាប្រភេទប្រេងឆៅធុនស្រាល (Light Crude Oil) ដែលមានការទិញលក់ច្រើនជាងគេ និងជាថ្លៃមូលដ្ឋានក្នុងការទិញលក់កិច្ចសន្យាអនាគត (Future Contract)។ ប្រេងឆៅលើទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នា ទៅតាមប្រភេទដូចជា÷ ប្រភេទប្រេង Brent ច្រើនផលិតនៅតំបន់សមុទ្រអាត្លង់ទិចខាងជើង, ប្រភេទប្រេងរបស់អាមេរិក WTI (West Texas Intermediate) និងប្រភេទប្រេងរបស់អារ៉ាប់ប៊ីសាអ៊ូឌីត Dubai។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈ ខុសគ្នាទៅតាមកម្រិតភាពស្រាល ហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់វាស់វែងភាពស្រាលនៃប្រភេទប្រេងឆៅនីមួយៗ។ ប្រភេទប្រេងដែលមានកម្រិត API Gravity កាន់តែខ្ពស់គឺជាប្រភេទប្រេងដែលកាន់តែស្រាល និងអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។

- WTI 40$^{o}$ API
- Brent 38$^{o}$ API
- Dubai 32$^{o}$ API

*រៀបចំដោយ*

*នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច*

*អគ្គនាយកដ្ឋានគោលនយោបាយ*

*ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ ០៧៧ ៨៨ ៩៩ ៩២, ០៩៨  ២២ ៨៤ ៩៤*

*ម៉ោងធ្វើការ÷ ៨:០០ ដល់ ១២:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*